THE UNIVERSITY OF AUCKLAND Te Whare Wānanga o Tāmaki Makaurau NEW ZEALAND | THE UNIVERSITY OF WESTERN AUSTRALIA | THE UNIVERSITY OF SYDNEY | USP THE UNIVERSITY OF THE SOUTH PACIFIC | Royal University of Phnom Penh

# ការបន្សាំទៅនឹងបំរែបំរួលអាកាសធាតុក្នុងការស្តារឡើងវិញបន្ទាប់ពីរងគ្រោះមហន្តរាយ៖ សេចក្តីសង្ខេបសម្រាប់គោលនយោបាយសង្ខេបទី ៤

## ការយល់ឃើញនៃផលប៉ះពាល់ដោយបំរែបំរួលអាកាសធាតុ និងយុទ្ធសាស្ត្របន្សាំសម្រាប់អនាគតបរិស្ថានមិនជាក់លាក់៖ លទ្ធផលពីយុវិធីសាស្ត្រចូលរួមក្នុងស្រុកព្រែកប្រសព្វ ខេត្តក្រចេះនៃព្រះរាជាណាចក្រកម្ពុជា


សេចក្ដីសង្ខេបសម្រាប់គោលនយោបាយនេះ បង្ហាញពីចក្ខុនៃការយល់ឃើញនៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្របន្សាំ/ដោះស្រាយផ្សេងៗនៃសហគមន៍រងផលប៉ះពាល់ដោយទឹកជំនន់នៅស្រុកព្រែកប្រសព្វ ខេត្តក្រចេះក្នុងព្រះរាជាណាចក្រកម្ពុជា។ វាបង្ហាញនូវអ្វីដែលសហគមន៍អាចដឹងបានទាក់ទងនឹងការប្រែប្រួលអាកាសធាតុបណ្តាលឲ្យកើតមានមុខសញ្ញាគ្រោះមហន្តរាយផលប៉ះពាល់នៃមុខសញ្ញាគ្រោះមហន្តរាយទៅលើការប្រកបរបរចិញ្ចឹមជីវិត សុខុមាលភាព និងវិធីសាស្ត្រសម្រាប់ បន្សាំ និងដោះស្រាយនឹងព្រឹត្តិការប្រែប្រួលសំខាន់ៗ និងការផ្លាស់ប្តូរបរិស្ថានតាមរដូវកាល។ សេចក្តីសង្ខេបនេះបង្ហាញពីការបញ្ចូលលទ្ធផលរួមគ្នាពីការធ្វើ ១៣ សិក្ខាសាលារួចមកហើយនៅក្នុងភូមិចំនួន ៤ ក្នុងឃុំ ២ ដោយប្រើវិធីសាស្ត្រឃ្យូ(Q-method)សកម្មភាពក្នុងការពិភាក្សាក្រុមជាមួយស្ត្រី បុរស និងក្មេងៗ ដើម្បីកំណត់នូវអ្វី ដែលបានយល់ឃើញថា រងផលប៉ះពាល់ជាងគេរបស់មហន្តរាយអាកាសធាតុ និងយន្តការដោះស្រាយទូទៅ។ ចំណេះដឹងរបស់អ្នកភូមិដែលបានផ្តល់នូវមូលដ្ឋានសម្រាប់ការយល់ដឹងពីរបៀបនៃការប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុនានា។ ចំណេះដឹងតាំងនោះ ត្រូវបានជួយឲ្យយើងដឹងពីមុខសញ្ញាគ្រោះថ្នាក់ និងរកដំណោះស្រាយនៅកំរិតសហគមន៍។


### សារជាគន្លឹះ

- ព្រះរាជាណាចក្រកម្ពុជានឹងជួបប្រទះការកើនឡើងនូវទឹកជំនន់ធំៗ និងគ្រោះរាំងស្ងួត និងថយចុះរបបទឹកភ្លៀងនារដូវវស្សា និងលំហូរទឹកទន្លេក្រោមការព្យាករណ៍អាកាសធាតុ។ បច្ចុប្បន្ននេះ តំបន់ជនបទមានបទពិសោធន៍ទៅនឹងគ្រោះរាំងស្ងួតខ្លាំងក្លា (ឆ្នាំ២០១៥-២០១៧) និងទឹកជំនន់ផ្សេងៗ (ឆ្នាំ ២០១៣ និង២០១៨)
- នៅក្នុងប្រើប្រាស់វិធីសាស្ត្រឃ្យូ (Q-method)នេះ សកម្មភាពពិភាក្សាជាក្រុមដោយប្រជាជននៅក្នុងសហគមន៍មូលដ្ឋាន ដើម្បីស្វែងយល់ ពីចំណេះដឹងអំពីកត្តាផ្សេងៗនៃបង្កឲ្យកើតមានមុខសញ្ញាគ្រោះមហន្តរាយមកពីអាកាសធាតុ ផលប៉ះពាល់នៃមុខសញ្ញាគ្រោះហន្តរាយទាំងនោះមកលើសហគមន៍


Funded by APN ASIA-PACIFIC NETWORK FOR GLOBAL CHANGE RESEARCH

និងវិធីសាស្ត្រដែលសហគមន៍យកទៅដោះស្រាយនឹងព្រឹត្តិការប្រែប្រួលរធំៗ និងការប្រែប្រួលបរិស្ថានរយៈពេលយូរអង្វែង។

- ជាទូទៅសហគមន៍អាចដឹងពីអាកាសធាតុ ដូចជាក្រៅជាងមុន និងរបបទឹកភ្លៀងតិច មានគ្រោះរាំងស្ងួតច្រើនជាងមុនដែលជាបញ្ហាប្រឈម ជាងទឹកជំនន់តាមរដូវកាល។ ការបន្សាំ និងយន្តការទប់ទល់សម្រាប់ទឹកជំនន់ បានរៀបចំយ៉ាងល្អ ប៉ុន្តែការកើនឡើងសីតុណ្ហភាព យុទ្ធសាស្ត្របន្សាំសម្រាប់គ្រោះរាំងស្ងួតនៅមិនទាន់មានការរៀបចំបានល្អនៅឡើយ ។

## បរិបទ

ព្រះរាជាណាចក្រកម្ពុជាបានទទួលរងផលប៉ះពាល់ដោយគ្រោះរាំងស្ងួតពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ និងបានជួបប្រទះការបំផ្លាញដោយទឹកជំនន់ក្នុងឆ្នាំ២០១១ ឆ្នាំ២០១៣ និងឆ្នាំ២០១៨។ ការព្យាករណ៍ថ្មីៗ



សម្រាប់ការប្រែប្រួលអាកាសធាតុនាពេលអនាគតបង្ហាញពីភាពងាយរងគ្រោះនៃរបរកសិកម្ម ដែលពឹងផ្អែកលើទឹកភ្លៀងនៅក្នុងអាងទន្លេមេគង្គក្រោម ស្របនឹងការប្រែប្រួលអាកាធាតុនៅតែបន្តកើនឡើង។ ជាការឆ្លើយតប រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុឆ្នាំ២០១៤-២០១៣។

ការស្រាវជ្រាវបានបង្ហាញពីការយល់ដឹងរបស់សហគមន៍ និងការស្វែងយល់ពីអាកាសធាតុទាក់ទងនឹងមហន្តរាយ និងការប្រែប្រួលបរិស្ថានរយៈពេលយូរ និងបានឲ្យដឹងពីការបន្សាំ និងយុទ្ធសាស្ត្រដោះស្រាយ ដែលពក់ព័ន្ធផ្ទាល់ដល់ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុរបស់ព្រះរាជាណាចក្រកម្ពុជា។ ការស្រាវជ្រាវ បានផ្តោតទៅលើភូមិបួននៅភាគខាងលិចនៃដងទន្លេមេគង្គ នៅចំងាយតែប៉ុន្មានគីឡូម៉ែត្រនៃភាគខាងត្បូងក្រុងក្រចេះ។ ភូមិ ដែលបានចុះការសិក្សារួមមានភូមិថ្មរៀប ភូមិអូរលុង ភូមិជីដុះក្រោម និងភូមិក្បាលកោះ។ សហគមន៍ទាំងនេះត្រូវបានគេជ្រើសរើសជាតំណាងរបស់សហគមន៍ ដែលទទួលរងផលប៉ះពាល់ដោយទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ តាមបណ្តោយដងទន្លេមេគង្គ រួមបញ្ចូលទាំងជីវិតរស់នៅកោះនៃទន្លេមេគង្គផងដែរ។ យ៉ាងហោចណាស់ មានសិក្ខាសាលាពិភាក្សាចំនួន ០២ ដង ក្នុងភូមិនីមួយៗនៃភូមិទាំងបួនត្រូវបានធ្វើឡើង។ អ្នកចូលរួមក្នុងសិក្ខាសាលា ត្រូវបានសួរឲ្យជ្រើសរើសខ្លឹមសារនៃបញ្ហាដែលរៀបចំ ដោយយោងតាមកំរិត ដែលពួកគេបានយល់ស្របតាម ឬមិនយល់ស្របតាម ជាមួយខ្លឹម

សារនៃបញ្ហានីមួយៗ។ ខ្លឹមសារនៃបញ្ហាចំនួន ១៦ ដំបូង ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អ្នកភូមិលើបញ្ហាផ្សេងៗ និងផលប៉ះពាល់នៃមុខសញ្ញាគ្រោះមហន្តរាយ ពិសេសព្រឹត្តិការទឹកជំនន់ និងគ្រោះរាំងស្ងួត។ ខ្លឹមសារនៃបញ្ហាចំនួន១៦ បន្ទាប់ ជាវិធីសាស្ត្រទប់ទល់ និងបន្សាំ។ សរុប ១៣ វគ្គនៃឃ្យូ(Q-sort)ត្រូវបានគេបំពេញដោយជោគជ័យ។

## ផលប៉ះពាលអាចដឹងបានពីមុខសញ្ញាគ្រោះថ្នាក់ និងបុព្វហេតុនៃការប្រែប្រួល




FIGURE 1: PERCEIVED DRIVERS FOR, AND IMPACTS FROM CLIMATE RELATED HAZARDS. FIGURE SHOWS RANGE OF RESPONSES FROM PARTICIPANTS (BARS) FOR EACH STATEMENT WITH CIRCLES REPRESENTING THE AVERAGE RESPONSE. RESULTS IN ORANGE SIGNIFY RESPONSES COMMON ACROSS ALL COMMUNITIES. RESULTS IN BLUE REPRESENT VIEWS UNIQUE TO A SUBSET OF COMMUNITIES.

ទោះជាបទពិសោធន៍រស់នៅមានភាពខុសៗគ្នាក្នុងចំណោមភូមិទាំងបួន ការយល់ដឹងជាទូទៅបានរកឃើញពីគ្រប់ភូមិ (រូបភាពទី១)។ គ្រោះរាំងស្ងួតត្រូវបាន គេដឹងថាមានការព្រួយបារម្ភកើនឡើង និងមានហានិភ័យដល់ការប្រកបរបរចិញ្ចឹមជីវិត។ លក្ខខណ្ឌទាំងនេះ ឆ្លុះបង្ហាញពីទិដ្ឋភាពសីតុណ្ហភាពកំពុងកើនឡើងជាទូទៅ ជាមួយនឹងការកើនឡើងនូវរបបភ្លៀងមិនទៀងទាត់។ ប្រជាជននៅក្នុងសហគមន៍នីមួយៗ បានយល់ឃើញថា គ្រោះរាំងស្ងួតជាលទ្ធផលផ្ទាល់នៃការបំផ្លាញព្រៃឈើ ក៏ដូចជាព្រឹត្តិការខ្យល់ខ្លាំងៗខុសពីធម្មតា។ ជារួម ទោះជាយ៉ាងណាក៏ដោយសហគមន៍នីមួយៗបានយល់ឃើញថាគ្រោះរាំងស្ងួតមានគ្រោះថ្នាក់ជាងគ្រោះទឹកជំនន់ រយៈពេលវែងនៃរដូវកាល និងខុសរដូវនៃទឹកជំនន់ក៏មានផលប៉ះពាល់ដល់ការចិញ្ចឹមជីវិតដែរ។ អ្នកភូមិបានយល់ឃើញថា ទឹកជំនន់ក៏ជាមធ្យោបាយសំខាន់សម្រាប់បំពេញ

បន្ថែមជីវជាតិដល់ដី ប៉ុន្តែមានការបារម្ភ លើគម្រោងវារីអគ្គីសនីក្នុងតំបន់អាងទន្លេមេគង្គលើ ដែលអាចនឹងធ្វើឲ្យមានការផ្លាស់ប្តូររបបទឹកប្រចាំឆ្នាំនាពេលអនាគត។

## យន្តការបន្សាំ និងទប់ទល់




ដ្យាក្រាម ២៖ ការបន្សាំ និងវិធីទប់ទល់មុខសញ្ញាគ្រោះមហន្តរាយបណ្តាលមកពីអាកាស។ រូបភាពបង្ហាញលំដាប់នៃចំលើយរបស់អ្នកចូលរួមទៅតាមខ្លឹមសារនៃបញ្ហានីមួយៗ ដោយមានគុសរង្វង់ជាតំណាងនៃការឆ្លើយតបជាមធ្យម។ លទ្ធផលពណ៌ទឹកក្រូច ជាសញ្ញាប្រាប់ពីការឆ្លើយរួមរបស់សហគមន៍ទាំងអស់។ លទ្ធផលពណ៌ខៀវបង្ហាញទស្សនជាក់ដោយឡែកៗពីគ្នានៃសហគមន៍ណីមួយៗ។

យន្តការទប់ទល់នានា សម្រាប់ឆ្លើយតបជាមួយទឹកជំនន់មានភាពខុសគ្នាបន្តិចបន្តួចពីភូមិមួយទៅភូមិមួយ ទោះជាយ៉ាងណា ការផ្លាស់ទីកន្លែងនៃទ្រព្យសម្បត្តិ និងការទុកដាក់គ្រឿងផ្គត់ផ្គង់ជីវភាព ដូចជាអាហារ គឺជាយន្តការទប់ទល់នៅគ្រប់ភូមិដែលបានសិក្សា(រូបភាពទី២)។ អ្នកភូមិបានយល់ឃើញថា ចំណេះដឹងរបស់ពួកគេ សម្រាប់ដោះស្រាយជាមួយឥទ្ធិពលទឹកជំនន់មានមិនគ្រប់គ្រាន់ កង្វះចំណេះដឹងសម្រាប់ដោះស្រាយជាមួយគ្រោះរាំងស្ងួតគឺជាចំណាប់អារម្មណ៍រួមនៅក្នុងក្រុមពិភាក្សានីមួយៗ។ សហគមន៍ខ្លះ បានបង្កើតការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ សម្រាប់ជាប្រព័ន្ធទប់ទល់នឹងបញ្ហា ដោយប្តូរមុខដំណាំផ្សេងពីការទទួលយកពូជស្រូវប្រាំងដែលដាំក្នុងរយៈពេលខ្លី។ ការផ្លាស់ប្តូរ ក្នុងការជ្រើសរើសមុខដំណាំ ពីការដាំថ្នាំជក់ ទៅជាដាំល្ង និងពោត បានកើតមានឡើងដោយសារកត្តា សុខភាព និងតម្រូវការទីផ្សារ។ ប៉ុន្តែ នៅពេលដែលប្រព័ន្ធស្រោចស្រព ត្រូវបានគេប្រើប្រាស់ជាយន្តការទប់ទល់សម្រាប់គ្រោះរាំងស្ងួត មិនមែនកសិករទាំងអស់ សុទ្ធតែប្រើយុទ្ធសាស្ត្រនេះទេ ដោយសារកត្តាហិរញ្ញវត្ថុ និង/ឬអាចមកពីស្ថានភាពភូមិសាស្ត្រ។

ក្នុងចំណោមសហគមន៍ទាំងអស់ កសិករបានកំពុងទិញដីចំការយ៉ាងកម្មនៅតំបន់ខ្ពស់ ដែលជាយុទ្ធសាស្ត្របន្សាំមួយ ហើយក៏មានយុទ្ធសាស្ត្រផ្សេងៗទៀតជាច្រើន ដូចជាអ្នកភូមិត្រូវបានបង្ខំចិត្តទៅស្វែងរកការងារធ្វើនោះខាងក្រៅសហគមន៍សម្រាប់ការចិញ្ចឹមជីវិតបន្ទាប់បន្សំ។ ទស្សនៈយល់ឃើញពី ការផ្លាស់ទីតាំង ជាយន្តការទប់ទល់ ឬជាវិធីសាស្ត្របន្សាំ ខុសៗគ្នាពីសហគមន៍មួយ ទៅសហគមន៍មួយ ដោយអ្នកភូមិមួយចំនួនមិនមានឆន្ទៈ ដើម្បីផ្លាស់ទីកន្លែងរហូតទេ។ អ្នកភូមិខ្លះៗទៀត បានគិតថាការចំណាកស្រុកជាជំរើសមួយ តែជំរើសនេះ ត្រូវបានគិតថាជាជាមធ្យោបាយមួយធ្វើឲ្យជីវភាពបានល្អប្រសើរ ។

ចំនួនអ្នកភូមិដែលធ្លាប់តែពឹងផ្អែកលើការគាំទ្រពីអ្នកនៅក្រៅសហគមន៍ មុនពេល កំឡុងពេល និងក្រោយពេល កើតមានព្រឹត្តិការណ៍គ្រោះមហន្តរាយ មានខុសៗគ្នាពីភូមិមួយទៅភូមិមួយទៀត។ ការគាំទ្រសហគមន៍ ចម្បងគឺក្នុងទម្រង់នៃកំលាំងពលកម្មស្ម័គ្រចិត្ត ជាមួយអ្នកចូលរួមមួយចំនួន បានបញ្ជាក់ថាការគាំទ្រខ្លះ ក្នុងទម្រង់នៃផ្តល់ម្ហូបអាហារពីអ្នកជិតខាង និងធ្វើប្រាក់ពីក្រៅមកឲ្យក៏ជាយន្តការទប់ទល់មួយដែរ។

ករណីភាគច្រើន អ្នកភូមិបានជឿជាក់យ៉ាងខ្លាំងតាមរយៈផ្សព្វផ្សាយព័ត៌មានពីអាកាសធាតុតាមមធ្យោបាយទូរទស្សន៍ និងវិទ្យុ ដោយការយល់ដឹងរបស់សហគមន៍ទៅលើជាសញ្ញាសម្គាល់នៃការប្រែប្រួលបរិស្ថានណាមួយប្រើលែងបាន។ នៅពេលសមាជិកសហគមន៍ ទទួលអារម្មណ៍ងាយស្រួលក្នុងការប្រើប្រាស់វិធីសាស្ត្ររបស់ពួកគេ ដើម្បីដោះស្រាយបញ្ហាទឹកជំនន់តាមរដូវ ដូចដែលគេធ្លាប់បានធ្វើកន្លងមកជាច្រើនជំនាន់ពួគេនឹងដោះស្រាយដោយខ្លួនឯង តែក៏នៅតែមានតម្រូវការរួមរបស់សហគមន៍ ដែលត្រូវការជួយគាំទ្រ ឬអន្តរាគមន៍ពីរដ្ឋាភិបាល ដូចជាករណីគ្រោះរាំងស្ងួតរយៈពេលយូរជាដើម ។

## ការប្រើប្រាស់សម្រាប់គោលនយោបាយ

- ការយល់ដឹងរបស់សហគមន៍មូលដ្ឋានពីមុខសញ្ញាគ្រោះមហន្តរាយអាកាសធាតុ និងបុព្វហេតុនៃការប្រែប្រួល ដែលបានបញ្ជាក់ដោយការព្យាករណ៍បែបវិទ្យាសាស្ត្រ ពីលំនាំនៃទឹកភ្លៀង ទឹកជំនន់ និងភាពរាំងស្ងួត បានក្លាយជាបញ្ហាមិនអាចព្យាករណ៍បាន នៅតាមបណ្តោយដងទន្លេមេគង្គក្រោម ក្នុងព្រះរាជាណាចក្រកម្ពុជា។ ករណីនេះមានផលប៉ះពាល់គួរឲ្យកត់សម្គាល់មួយដល់សហគមន៍ ពាក់ព័ន្ធទៅលើប្រភពប្រាក់ចំណូលជាចំបង ពីការធ្វើស្រែ និងការនេសាទ។
- ភាពផ្សេងៗគ្នានៃលំនាំអាកាសធាតុ និងគ្រោះរាំងស្ងួត ហាក់ដូចជា លក្ខខណ្ឌ ដែលមានការបារម្ភយ៉ាងខ្លាំងរបស់សហគមន៍ទាំងនេះ ដោយសារការយល់ដឹងមានដែនកំណត់ អំពីវិធីបន្សាំទៅនឹងការកើនឡើងសីតុណ្ហភាព និងលំនាំរបបទឹកភ្លៀងមិនទាងទាត់ ។
- សហគមន៍នីមួយៗបានអភិវឌ្ឍ យុទ្ធសាស្ត្រមួយចំនួនសម្រាប់បន្សាំកសិកម្មរបស់ពួកគេ និងការប្រកបរបរចិញ្ចឹមជីវិត និងកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេ ទៅនឹងការព្រួយបារម្ភជាប្រចាំ ពីគ្រោះរាំងស្ងួតខ្លាំង និងទឹកជំនន់ផ្សេងៗ។ គ្រោះរាំងស្ងួតគឺទាក់ទងនឹងអភូតហេតុថ្មីរបស់អ្នកភូមិ ដែលតម្រូវ

ឲ្យមានការយកចិត្តទុកដាក់ពីអ្នកបង្កើតគោលនយោបាយ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។

- សហគមន៍នីមួយៗគឺកំពុងសំលឹងទៅលើរដ្ឋាភិបាល ដើម្បីផ្តល់ការជួយគាំទ្រ សម្រាប់ការបន្សាំទៅមុខសញ្ញាគ្រោះមហន្តរាយអាកាសធាតុ ទាំងក្នុងលក្ខខណ្ឌនៃចំណេះដឹង និងគោលការណ៍ណែនាំ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។
- វិធីសាស្ត្រឃ្យូ (Q-method)បានបង្ហាញឲ្យដឹងថា ឧបករណ៍មានប្រយោជន៍ ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យដែលបានរកឃើញដោយវិធីសាស្ត្រផ្សេងៗ ដូចជាការគូសផែនទីគ្រោះមហន្តរាយដោយមានការចូលរួម និងការអង្កេតជាប្រព័ន្ធនៅតាមខ្នងផ្ទះ។ ផ្អែកតាមបទពិសោធន៍របស់សហគមន៍ និងចំណេះដឹងពិតជាអាចផ្តល់ជាព័ត៌មាន សម្រាប់ការបង្កើតគោលនយោបាយ ដើម្បីអន្តរាគមន៍ពីខាងក្រៅទាក់ទងទៅនឹងវិធានការកាត់បន្ថយ និងការបន្សាំ។

## SOURCE

This policy brief has been prepared by Dr Bryan Boruff, The University of Western Australia, and is based on the following material:

Boruff, B., Neef, A., Hak, S., Touch, S., and Ngin, C., (2019) Climate change impacts and adaptation strategies in rural Cambodia: perceptions from flood-affected communities in Kratie (in draft).

Edited by Professor Andreas Neef, The University of Auckland, New Zealand

**About this publication:** This policy brief has been developed for the APN project "Climate Change Adaptation in Post-Disaster Recovery Processes: Flood-Affected Communities in Cambodia and Fiji" (CAF2017-RR01-CMY-Neef) under APN's Climate Adaptation Framework. For full details of this project, including news and events, project activities, publications and presentations, please visit the project website at http://www.climatechangeplus.net.

April 2019